# រោគ ធូឡារ៉េមា (Tularemia)

រោគ ធូឡារ៉េមា គឺជារោគមួយយ៉ាងធ្ងន់ធ្ងរ។ រោគនោះកើតឡើងដោយមេរោគ ដែលជួនកាលរកឃើញនៅក្នុងសត្វកណ្ដុរ, ទន្សាយ ហើយនិងសត្វព្រៃផ្សេងៗទៀត។

## តើខ្ញុំប្រហែលជាអាចមានរោគ ធូលារ៉េមា ដោយរបៀបណា ?

លោកអ្នកប្រហែលជាអាចមានរោគ ធូឡារ៉េមា បានបើសិនជាលោកអ្នក :

- កាន់សត្វស្លាប់ទាំងឡាយដែលមានមេរោគ,
- បានខាំដោយសត្វចៃ, សត្វហើរល្អិត ឬសត្វល្អិតផ្សេងៗដែលមានរោគឆ្លង,
- បរិភោគម្ហូបអាហារ ឬផឹកទឹកដែលមិនស្អាត, ឬ
- ស្រូបដង្ហើមចូលមេរោគដែលបណ្ដាលឲ្យកើតរោគ ធូឡារ៉េមា ។

## តើរោគ ធូឡារ៉េមា គ្រោះថ្នាក់ឬទេ ?

គ្រោះថ្នាក់។ លោកអ្នកត្រូវតែព្យាបាលដោយអង់ទីប៊ីយោទិក (បដិបក្ខប្រាណ) ***ភ្លាម***ៗ, ឬលោកអ្នកប្រហែលជាអាចស្លាប់បាន។ ការព្យាបាលជាមួយថ្នាំផ្សះ, លោកអ្នកប្រហែលនឹងអាចរស់រានមានជីវិតបាន។



## តើរោគសញ្ញា ធូឡារ៉េមា មានសភាពដូចម្ដេចដែរ ?

រោគសញ្ញាដំបូងកើតមានឡើងក្នុងកំឡុងពេលពី 3-5 ថ្ងៃ :

- កើតមានជម្ងឺគ្រុនភ្លាមៗ, គ្រុនរងា,
- ហើមក្រពេញ, ឈឺខ្លាំង,
- ឈឺក្បាល,
- រោគចុះរាគ,
- ឈឺចុកសាច់ដុំ និងសន្លាក់,
- ក្អកស្ងួត,
- ទន់ខ្សោយ។

រោគសញ្ញាផ្សេងៗទៀត គឺវាអាស្រ័យលើវិធីដែលលោកអ្នកបានឆ្លងមេរោគ។ លោកអ្នក ប្រហែលជាអាចឈឺលើស្បែក ឬមាត់, ឈឺបំពង់ក, ហើមនិងឈឺក្នុងភ្នែក ឬក្រពេញនៅក្នុងក, ខាងក្រោមដៃ ឬក្រលៀន។

ពេលក្រោយមកទៀត លោកអ្នកប្រហែលជាអាចមានជម្ងឺហើមសួត ហើយដកដង្ហើមហត់ៗ, ឈឺចុកទ្រូង ហើយក្អកមានឈាមអន្ធិលៗ។ មានមនុស្សខ្លះ ឈប់ដកដង្ហើមហើយស្លាប់។

## តើរោគ ធូឡារ៉េមា ឆ្លងឬទេ ?

ទេ។ លោកអ្នកមិនអាចឆ្លងរោគ ធូឡារ៉េមា ពីអ្នកដទៃបានទេ។

## តើមានថ្នាំ វ៉ាក់ស៊ីន ចាក់ការពារទេ ?

មិនមានទេ។

## តើខ្ញុំធ្វើយ៉ាងណាបើសិនជាខ្ញុំគិតថាមានរោគ ធូឡារ៉េមា នោះ ?

ទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក ឬមន្ទីរពេទ្យ***ភ្លាម***។



## តើអាចឲ្យខ្ញុំការពារកុំឲ្យឆ្លងរោគនេះដោយរបៀបណា ?

លោកអ្នកអាច :

- ការពារកុំឲ្យសត្វល្អិតខាំ,
  - ប្រើថ្នាំលាបកុំឲ្យសត្វល្អិតមកជិតដែលមានជាតិ DEET នៅលើស្បែក, ហើយ
  - បាញ់ថ្នាំកុំឲ្យសត្វល្អិតមកជិតបានលើខោអាវដែលមានជាតិថ្នាំរោគស្បែក (permethrin) ។
- លាងដៃរបស់លោកអ្នកឲ្យបានញឹកញាប់ជាមួយសាប៊ូនិងទឹកក្ដៅអ៊ុនៗ, ជាពិសេសក្រោយពីបានកាន់សត្វងាប់,
- តែងតែចំអិនម្ហូបអាហាររបស់លោកអ្នកបានឆ្អិន, ហើយ
- ធ្វើយ៉ាងណាទឹកប្រើប្រាស់របស់លោកអ្នកបានមកពីប្រភពស្អាត។

ទូរស័ព្ទទៅពេទ្យសត្វ បើសិនជាសត្វស្រុក និងសត្វចិញ្ចឹមរបស់លោកអ្នក (ជាពិសេសសត្វ ទន្សាយ, កណ្ដុរ, និងសត្វកកេរផ្សេងៗទៀត) ចាប់ផ្ដើមកើតមានរោគសញ្ញាខុសធម្មតា ដូចជាជម្ងឺ គ្រុន, ចុះទម្ងន់, ហើមក្រពេញ, ដំបៅ, ។ល។

## តើភេរវជនអាចប្រើរោគ ធូឡារ៉េមា ជាអាវុធបានទេ ?

វាអាចបាន, ក៏ប៉ុន្តែវាមានការពិបាកក្នុងការបញ្ចេញមេរោគ ធូឡារ៉េមា គ្រប់គ្រាន់នៅក្នុងខ្យល់។

## សំរាប់ពត៌មានបន្ថែម...

ទូរស័ព្ទទៅ CDC (Centers for Disease Control) សំរាប់ពត៌មានជាភាសាអង់គ្លេស :

800-CDC-INFO (800-232-4636)<br>888-232-6348 (TTY)

ឬទស្សនាគេហទំព័រ : www.bt.cdc.gov/agent/tularemia<br>www.dhs.ca.gov/epo